ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិនៃកម្ពុជា

លេខ.ធ.ជ.០១៩.០៤៩

សេចក្តីប្រកាសព័ត៌មាន
ពិធីផ្សព្វផ្សាយសៀវភៅស្តីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ
ប្រចាំឆ្នាំ២០១៨

ថ្ងៃពុធ ៥រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩

នៅថ្ងៃពុធ ៥រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជា បានរៀបចំពិធីផ្សព្វផ្សាយសៀវភៅស្តីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៨ នៅសាលប្រជុំ ផ្សារទំនើប អ៊ីអនមល សែនសុខ ស៊ីធី។ ពិធីនេះត្រូវបានរៀបចំឡើងក្រោមអធិបតីភាព លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា និងបានអញ្ជើញចូលរួមពីតំណាងក្រសួងស្ថាប័ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ វិទ្យាស្ថានស្រាវជ្រាវ អ្នកវាយតម្លៃនិងភ្នាក់ងារអចលនទ្រព្យ និងដៃគូរអភិវឌ្ឍន៍នានា សរុបប្រមាណ ៤០០នាក់។

ចាប់តាំងពីឆ្នាំ២០១១មក ធនាគារជាតិនៃកម្ពុជាបានបង្កើតគណៈកម្មាធិការស្ថិរភាពហិរញ្ញវត្ថុ ដើម្បីតាមដាន និងវិភាគហានិភ័យនានាដែលពាក់ព័ន្ធដល់ស្ថិរភាពហិរញ្ញវត្ថុ។ ដោយសារស្ថិរភាពហិរញ្ញវត្ថុមានសារៈសំខាន់ក្នុងការគាំទ្រដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជួយជំរុញកំណើន ធនាគារជាតិនៃកម្ពុជាបានរៀបចំសៀវភៅស្តីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុសម្រាប់សាធារណជនទូទៅ និងភាគីពាក់ព័ន្ធ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងឱ្យកាន់តែប្រសើរឡើងលើការវិវឌ្ឍ និងហានិភ័យនានាពាក់ព័ន្ធនឹងស្ថិរភាព និងគោលនយោបាយហិរញ្ញវត្ថុ។

អត្ថបទសង្ខេបនៃសៀវភៅស្តីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៨ ត្រូវបានភ្ជាប់ជូនជាមួយសេចក្តីប្រកាសព័ត៌មាននេះ។

សូមទំនាក់ទំនង៖
ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
ទូរស័ព្ទ៖ ០២៣ ៩៩០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh